# សុន្ទរកថាបើក និង របាយការណ៍
# ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងផែនការ
# ថ្លែងក្នុងឱកាសទិវាប្រជាជនពិភពលោកលើកទី៣០, ១១ កក្កដា
# និង ខួប២៥ឆ្នាំ នៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ (ICPD25)

- **លោកស្រី Rizvina de Alwis តំណាង UNFPA ប្រចាំប្រទេសកម្ពុជា**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា**
- **ឯកឧត្តម លោកជំទាវ តំណាងឯកអគ្គរដ្ឋទូត តំណាងដៃគូអភិវឌ្ឍន៍នានា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា**
- **ក្មួយៗនិស្សិត ជាទីស្រឡាញ់រាប់អាន**

**១.** ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានចូលរួមជាអធិបតីជាមួយនឹង ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ក្នុង**ទិវាប្រជាជនពិភពលោកលើកទី៣០, ១១ កក្កដា និង ខួប២៥ឆ្នាំ នៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ** (ICPD25) នាពេលនេះ។ ក្នុងនាមក្រសួងផែនការ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមឆ្លៀតយកឱកាសដ៏មានតម្លៃនេះ សម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលជាតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ តំណាងឯកអគ្គរដ្ឋទូត តំណាងដៃគូអភិវឌ្ឍន៍នានា និងតំណាងអង្គការសង្គមស៊ីវិល និងក្មួយៗយុវនិស្សិតមកពីសកលវិទ្យាល័យ ដែលមានវត្តមាន នាពេលនេះ។

**២.** ខ្ញុំសូមឆ្លៀតយកឱកាសនេះ ដើម្បីរំលឹកអំពីប្រវត្តិសង្ខេប នៃការប្រារព្ធទិវាប្រជាជនពិភពលោក ជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ក្មួយៗយុវនិស្សិត និងអង្គពិធីជ្រាបថា ក្រុមប្រឹក្សាភិបាល នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បានបង្កើតនិងប្រារព្ធទិវាប្រជាជនពិភពលោកលើកដំបូងនៅឆ្នាំ១៩៨៩ ក្នុងគោលបំណងដើម្បីផ្តល់នូវការស្វែងយល់ឲ្យកាន់តែស៊ីជម្រៅអំពីបញ្ហាប្រជាជននៅក្នុងពិភពលោក។ អង្គការសហប្រជាជាតិ បានកំណត់យកថ្ងៃទី១១ ខែកក្កដា ដើម្បីប្រារព្ធទិវាប្រជាជនពិភពលោកជារៀងរាល់ឆ្នាំ ដោយផ្តោតលើប្រធានបទផ្សេងៗគ្នា។ ជាមួយគ្នានេះដែរ អង្គការសហប្រជាជាតិ បានអំពាវនាវ

ដល់បណ្ដាប្រទេសជារដ្ឋភាគីទាំងអស់ ឲ្យប្រារព្ធទិវាប្រជាជនពិភពលោកនៅតាមបណ្ដាប្រទេសរៀងៗខ្លួន ដើម្បីរំលឹកនិងបន្តផ្ដោតការយកចិត្តទុកដាក់ទៅលើបញ្ហាប្រជាជន និងឌីណាមិកប្រជាសាស្ត្រ ដែលបាននិងកំពុងកើតមាន ហើយនឹងអាចកើតមាននាពេលខាងមុខនៅក្នុងប្រទេសនីមួយៗ និងចាត់ទុកប្រជាជនជាកត្តាគន្លឹះសម្រាប់ការអភិវឌ្ឍ។

៣. ប្រធានបទឆ្នាំនេះ ផ្ដោតលើ**ខួប២៥ឆ្នាំ នៃសន្និសីទអន្តរជាតិស្ដីពីប្រជាជននិងការអភិវឌ្ឍ** (ICPD25)។ ប្រធានបទនេះ ពិតជាមានអត្ថន័យដ៏ធំធេង ក្នុងបំណងឆ្លុះបញ្ចាំងអំពីសមិទ្ធផលសំខាន់ៗ ដែលប្រជាជាតិនីមួយៗសម្រេចបានក្នុងរយៈពេល២៥ឆ្នាំកន្លងមកក្នុងការនុវត្តផែនការសកម្មភាព នៃសន្និសីទអន្តរជាតិស្ដីពីប្រជាជននិងការអភិវឌ្ឍនៅទីក្រុងគែរ ប្រទេសអេហ្ស៊ីប ឆ្នាំ១៩៩៤ ដែលសន្និសីទនេះបានទទួលស្គាល់អំពីទំនាក់ទំនងទៅវិញទៅមករវាងប្រជាជននិងការអភិវឌ្ឍ និងអំពាវនាវឲ្យមានការយកចិត្តទុកដាក់ខ្ពស់ចំពោះការផ្ដល់ភាពអង់អាចដល់ស្ត្រី ការលើកកម្ពស់សុខភាពបន្តពូជនិងសិទ្ធិរបស់ស្ត្រី និងការដាក់បញ្ចូលបញ្ហានេះទៅក្នុងដំណើរការ នៃការអភិវឌ្ឍជាតិ តំបន់ និងសកល។

៤. កម្ពុជា តាមរយៈក្រសួងផែនការ សហការជាមួយ UNFPA និងស្ថាប័នពាក់ព័ន្ធ បានប្រារព្ធទិវាប្រជាជនពិភពលោកជារៀងរាល់ឆ្នាំ ក្នុងគោលបំណងដើម្បីរំលឹក និងជំរុញបន្ថែមដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ បញ្ញវន្ត សិស្ស និស្សិត និងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ព្រមទាំងប្រជាពលរដ្ឋគ្រប់រូប ឲ្យបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីបុព្វហេតុប្រជាជននិងការអភិវឌ្ឍ ជាពិសេស កិច្ចខិតខំប្រឹងប្រែងស្វែងរកដំណោះស្រាយទាក់ទងនឹងកត្តាឌីណាមិកប្រជាសាស្ត្រ ដែលកំពុងជះឥទ្ធិពលដល់ការអភិវឌ្ឍ។ សូមរំលឹកថា ជារៀងរាល់ឆ្នាំ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្ញើសារលិខិតអបអរសាទរ និងជូនពរដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបនាឱកាសនៃការប្រារព្ធ**ទិវាប្រជាជនពិភពលោក ១១ កក្កដា** នេះ។

៥. ឆ្នាំ២០១៩នេះ ជាឆ្នាំពិសេស ដែលក្រសួងផែនការ សហការជាមួយនឹងក្រសួងសុខាភិបាល និង UNFPA ប្រារព្ធធ្វើ**ទិវាប្រជាជនពិភពលោកលើកទី៣០**នេះ រួមគ្នាជាមួយនឹង**ខួប២៥ឆ្នាំនៃសន្និសីទអន្តរជាតិស្ដីពីប្រជាជននិងការអភិវឌ្ឍ** និងខួប២៥ឆ្នាំរបស់ UNFPA ដែលមានវត្តមាននិងប្រតិបត្តិការនៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ផងដែរ។ កិច្ចសហការរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹង UNFPA និងដៃគូអភិវឌ្ឍន៍នានា ក្នុងរយៈពេល

២៥ឆ្នាំនេះ បាននាំឲ្យកម្ពុជាសម្រេច បាននូវសមិទ្ធិផលធំៗលើគ្រប់វិស័យគួរឲ្យកត់សម្គាល់ ដូចដែលបានលើកឡើងនៅក្នុងសារលិខិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តី នៃព្រះរាជាណាចក្រកម្ពុជា** ដែលអានដោយ**ឯកឧត្តម ជា ចាន់ទុំ អគ្គលេខា-ធិការ** នៃអគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍ នៃក្រសួងផែនការ មុននេះបន្តិច។

**៦.** ក្នុងន័យនេះ ខ្ញុំសូមគូសបញ្ជាក់ឡើងវិញ អំពីសូចនាករសំខាន់ៗមួយចំនួន បង្ហាញពីសមិទ្ធិផលធំៗ ដែលកម្ពុជាសម្រេចបានក្នុងរយៈពេល២៥ឆ្នាំកន្លងមកនេះ ក្នុងការអនុវត្តផែនការសម្មភាព នៃសន្និសីទអន្តរជាតិស្តីពីប្រជាជនិងការអភិវឌ្ឍ រួមមានដូចជា៖ អត្រាភាពក្រីក្រ បានថយចុះពី ៤៧% នៅឆ្នាំ២០០៧ មកនៅត្រឹមរង្វង់ប្រមាណ ១៣,៥% នៅឆ្នាំ២០១៤។ អត្រាមរណភាពមាតា បានថយចុះពី ៤៣៧នាក់ ក្នុងចំណោមទារកកើតរស់ ១០០ ០០០ នាក់នៅឆ្នាំ២០០០ ដល់ ១៧០នាក់ នៅឆ្នាំ២០១៤ ហើយនឹងបន្តថយចុះដល់ ៦៥នាក់ នៅឆ្នាំ២០២០។ អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំបានថយចុះពី ១២៥នាក់ ក្នុង ១ ០០០កំណើតរស់ នៅឆ្នាំ២០០០ មកត្រឹម ៣៥នាក់ ក្នុង ១ ០០០ កំណើតរស់ នៅឆ្នាំ២០១៤។ អត្រាអក្ខរកម្មរបស់មនុស្សពេញវ័យ (ចាប់ពី១៥ឆ្នាំឡើង) បានកើនពី ៧៧,៦% នៅឆ្នាំ២០០៨ ដល់ ៨២,៥ % នៅឆ្នាំ២០១៨។ អាយុសង្ឃឹមរស់របស់ប្រជាជនកម្ពុជា បានកើនពី ៥៥ឆ្នាំ នៅ ឆ្នាំ១៩៩៥ ដល់ ៦១ឆ្នាំ នៅឆ្នាំ២០១០ (ក្នុងនោះអាយុបុរសកើនឡើងពី ៥៤ឆ្នាំ ទៅ ៦០ឆ្នាំ និងអាយុស្រ្តី កើនពី៥៧ឆ្នាំ ទៅ៦៣ឆ្នាំ)។ មកដល់ឆ្នាំ២០១៨ អាយុសង្ឃឹមរស់របស់បុរសកើនដល់ ៦៨ឆ្នាំ និងអាយុស្ត្រីកើនដល់ ៧២ឆ្នាំ។ ផលិតផលសរុបក្នុងស្រុកសម្រាប់មនុស្សម្នាក់ៗ បានកើនពី ៧៣៨ដុល្លារអាមេរិក នៅឆ្នាំ២០០៨ ដល់ ១ ៥៤៨ដុល្លារអាមេរិក នៅឆ្នាំ២០១៨។

**៧.** លើសពីនេះទៀត ក្នុងក្របខ័ណ្ឌនៃកិច្ចសហការដោយផ្ទាល់ រវាងក្រសួងផែនការជាមួយនឹង UNFPA ក៏ដូចជាមួយនឹងដៃគូរអភិវឌ្ឍន៍នានា សមិទ្ធិផលធំៗជាច្រើន ដែលយើងសម្រេចបាន រួមមានដូចជា៖ ជំរឿនទូទៅប្រជារាស្ត្រឆ្នាំ១៩៩៨ ឆ្នាំ២០០៨ និងជំរឿនទូទៅប្រជារាស្ត្រប្រឆ្នាំ២០១៩ ដែលនឹងប្រកាសលទ្ធផលបណ្តោះអាសន្ននាពេលខាងមុខនេះ ការគាំទ្រដល់ដំណើរការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ គោលនយោបាយជាតិប្រជាជន គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ព្រមទាំងអង្កេតផ្សេងៗជាច្រើន។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ក្មួយៗនិស្សិត ជាទីរាប់អាន!

៨. ទោះបីរាជរដ្ឋាភិបាល ខិតខំប្រឹងប្រែងសម្រេចបាននូវសមិទ្ធផលដ៏ធំធេងគួរឱ្យកត់សម្គាល់ដូចបានលើកឡើងនេះក្តី ក៏នៅមិនទាន់ឈានដល់កម្រិតដែលយើងចង់បាននៅឡើយ ជាពិសេស បញ្ហាប្រឈមចម្បងៗទាក់ទងនឹងគុណភាពសេវា ទាំងក្នុងវិស័យសុខាភិបាល ទាំងក្នុងវិស័យអប់រំ ក៏ដូចជាវិស័យផ្សេងៗទៀត។ អាទិភាពបន្តរបស់យើង គឺកែលម្អសេវាសុខភាព និងផ្តល់លទ្ធភាពគ្រប់គ្រាន់ដល់គូស្រករ ក្នុងការទទួលបានសេវាសុខភាពបន្តពូជ ជាពិសេស ស្ត្រីនិងក្មេងស្រី នូវជម្រើសក្នុងការធ្វើផែនការពន្យាកំណើត ដើម្បីពួកគាត់អាចមានឱកាសសិក្សាបានខ្ពស់ និងចូលរួមអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ និងប្រទេសជាតិ។

៩. ក្នុងន័យនេះ យើងត្រូវចូលរួមទាំងអស់គ្នា ដើម្បីកែលម្អគុណភាពសេវាសាធារណៈ ជាពិសេស សេវាសុខាភិបាល សំដៅសម្រេចឲ្យបាននូវអាទិភាពទាំងឡាយ ដែលបានលើកឡើងនៅក្នុងយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយជាតិប្រជាជន និងផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ និង គឺការលើកកម្ពស់សិទ្ធិរបស់ស្ត្រី និងសុខុមាលភាពរបស់មាតានិងទារក។

១០. ដូច្នេះ ដើម្បីធានាឲ្យបាននូវជោគជ័យក្នុងការបន្តការអនុវត្តផែនការសកម្មភាព នៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍសម្រាប់ពេលខាងមុខ ទាមទារឲ្យមានកិច្ច-សហការ និងកិច្ចខិតខំប្រឹងប្រែងរួមគ្នា រវាងក្រសួង ស្ថាប័ន និងមន្ទីរជំនាញ និងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ សំដៅប្រែក្លាយគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល ឲ្យទៅជាការអនុវត្តជាក់ស្តែង និងបន្តគាំទ្រនិងចូលរួមដោះស្រាយបញ្ហាប្រជាជននិងការអភិវឌ្ឍប្រកបដោយគុណភាព។

១១. ជាមួយនឹងការអបអរខួប២៥ឆ្នាំនៃការអនុវត្តផែនការសកម្មភាព នៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ ក៏ដូចជាខួប២៥ឆ្នាំរបស់មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជនដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជា ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់របស់ក្រសួងផែនការ ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលទាំងឡាយ ដែលស្ថាប័ននេះសម្រេចបាន ក្នុងភាពជាដៃគូជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍដទៃទៀត ជាពិសេស ភាពជាដៃគូផ្ទាល់ជាមួយនឹង

ក្រសួងផែនការ។ ខ្ញុំក៏សូមលើកទឹកចិត្ត និងអំពាវនាវដល់ UNFPA និងអង្គការសហប្រជាជាតិនានា ព្រមទាំងដៃគូអភិវឌ្ឍន៍ទាំងអស់ បន្តកិច្ចសហការ និងគាំទ្រដល់កម្ពុជា។ ខ្ញុំមានការជឿជាក់ចំពោះសុឆន្ទៈក្នុងការពង្រឹង និងលើកកម្ពស់កិច្ចសហប្រតិបត្តិការអភិវឌ្ឍឲ្យកាន់តែល្អប្រសើរនិងសកម្មថែមទៀត ដើម្បីគោលដៅរួមរបស់យើងទាំងអស់គ្នា គឺ **"ការកសាងពិភពលោកមួយដែលគ្មាននរណាម្នាក់ត្រូវបានបំភ្លេចចោល"**

**១២.** ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងក្មួយៗនិស្សិតទាំងអស់មានសុខភាពល្អ ទទួលបាននូវជ័យជំនះគ្រប់ភារកិច្ច និងសូមទទួលបាននូវពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបើកជាផ្លូវការ **ទិវាប្រជាជនពិភពលោកលើកទី៣០** និង **ខួប២៥ឆ្នាំនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ** ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**